ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងកូវីដ-១៩ សម្រាប់ជុំទី៦ លើកទី៣ និងការបើកសាច់ប្រាក់ជុំទី៧ លើកទី១

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានចាប់ផ្តើមដំណើរការអនុវត្តកម្មវិធីនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ មកដល់បច្ចុប្បន្នបានចំនួន ៦ជុំ មាន ១៦លើក រួចមកហើយ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា គិតត្រឹមថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៨:០០ ការបើកផ្តល់ជុំទី៦ លើកទី៣ ត្រូវបានបញ្ចប់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

| | ចំនួនគ្រួសារ | | ចំនួនសមាជិក | កុមារអាយុពី ០-៥ ឆ្នាំ | មនុស្សចាស់អាយុពី ៦០ឆ្នាំ | ជនមានពិការភាព | គ្រួសារដែលមានជំងឺអេដស៍ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|
| | ក្រ១ | ក្រ២ | | | | | | |
| ទីប្រជុំជនក្នុងរាជធានី | 2,124 | 2,805 | 21,914 | 941 | 3,585 | 2,656 | 8 | 1,772,536,000 |
| ទីប្រជុំជនក្រៅរាជធានី | 15,815 | 14,113 | 132,535 | 9,775 | 15,161 | 5,338 | 5 | 9,179,164,000 |
| ជនបទ | 233,317 | 410,285 | 2,523,590 | 196,169 | 316,283 | 53,432 | 1,945 | 109,546,056,000 |
| សរុបគ្រួសារដែលបានទទួលសេវាឧបត្ថម្ភ | 251,256 | 427,203 | 2,678,039 | 206,885 | 335,029 | 61,426 | 1,958 | 120,497,756,000 |
| | 678,459 | | | | | | | |

(មួយរយម្ភៃពាន់ លានបួនរយកៅសិបប្រាំពីរលាន ប្រាំពីររយហាសិបប្រាំមួយពាន់ រៀលគត់)

ទន្ទឹមនេះផងដែរ រាជរដ្ឋាភិបាលបានផ្តល់ការអន្តរាគមន៍ក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាជនក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ បានចំណាយថវិការដ្ឋ ១,៩៨៣,៧៤៤,៩០២,០០០ (**មួយពាន់ប្រាំបួនរយប៉ែតសិបបីពាន់លាន ប្រាំពីររយសែសិបបួនលាន ប្រាំបួនរយពីរពាន់រៀលគត់ ស្មើនឹង ៤៩០.៥៤ លានដុល្លារអាមេរិក**)។

ព្រមជាមួយគ្នានេះផងដែរ សម្រាប់ការបើកផ្តល់ប្រាក់ឧបត្ថម្ភជុំទី៧ លើកទី១ នឹងចាប់ផ្តើមពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ មានរយៈពេល ៣០ថ្ងៃ និងត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ចំពោះគ្រួសារដែលបានផ្ទៀងផ្ទាត់ទាំង ១៥លើក រួចហើយ សូមអញ្ជើញទៅបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងណាមួយដោយមិនតម្រូវឱ្យទៅសាលាឃុំ សង្កាត់ សារជាថ្មីទៀតទេ
- ចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌មានជុំទី១១ ទាំងអស់ត្រូវបានផុតសុពលភាពនៃការប្រើប្រាស់ប័ណ្ណចាស់ ហើយដោយជំនួសមកវិញដោយប័ណ្ណជុំទី១៤ វិញ ដែលករណីនេះបើមិនមានការជូនដំណឹង ឬ ផ្តល់ព័ត៌មានពីរដ្ឋបាលឃុំសង្កាត់ក្នុងការផ្តល់ប័ណ្ណថ្មីជុំទី១៤ ទេនោះ មានន័យថា គ្រួសារដែលមានប័ណ្ណជុំទី១១ នោះមិនបានជាប់ជុំទី ១៤បន្តទៀតទេ
- ចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌មានជុំទី១១ ដែលបានជាប់បន្តទៅជុំទី១៤ ត្រូវយកប័ណ្ណថ្មី ដែលផ្តល់ដោយរដ្ឋបាល ឃុំ សង្កាត់ ដើម្បីយកទៅបើកសាច់ប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងដូចធម្មតា ដោយមិនតម្រូវឲ្យទៅផ្ទៀងផ្ទាត់ឡើងវិញនៅតាម ឃុំ សង្កាត់ នោះទេ លើកលែងតែគ្រួសារ ដែលជាប់ថ្មីនៅជុំទី១៤ ត្រូវទៅផ្ទៀងផ្ទាត់នៅតាម ឃុំ សង្កាត់ ជាមុនសិន មុនទៅបើកប្រាក់នៅតាមបញ្ជរវីង
- ករណីគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌មានជុំទី១១ មិនបានជាប់នៅក្នុងជុំទី១៤ បន្តទៀត តែបានផ្ទៀងផ្ទាត់រួចហើយនៅតាម ឃុំ សង្កាត់ និងមានលុយនៅសល់ក្នុងគណនីរបស់ខ្លួននោះ អ្នកទទួលផលនៅអាចប្រើប្រាស់ប័ណ្ណជុំទី១១ ដើម្បីដកប្រាក់ ដែលនៅសល់នោះនៅគ្រប់បញ្ជរវីងបាន តែអ្នកទទួលផលនោះមិនបានទទួលការឧបត្ថម្ភបន្តទៀតនោះទេ
- ក្នុងករណីមានការតវ៉ា ឬ មានចម្ងល់របស់អ្នកទទួលផល ដែលប្តូរជុំពីជុំទី១១ ទៅជុំទី១៤ នោះ សូមទំនាក់ទំនងទៅរដ្ឋបាលឃុំ សង្កាត់ ឬ មន្ទីរផែនការ រាជធានី ខេត្ត
- ចំពោះគ្រួសារដែលបានផ្ទៀងផ្ទាត់ទាំង ៦ជុំ(១៦លើក) រួចហើយ លើកលែងតែជុំទី១១ ដែលមិនបានជាប់ជុំទី១៤ សូមអញ្ជើញទៅបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងណាមួយ ដោយមិនតម្រូវឱ្យទៅសាលាឃុំ សង្កាត់ សារជាថ្មីទៀតទេ
- ចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌មានសុពលភាព ហើយមិនទាន់បានផ្ទៀងផ្ទាត់ទាំង ៦ជុំ(១៦លើក) និងគ្រួសារក្រីក្រ ដែលទើបទទួលបានប័ណ្ណសមធម៌ថ្មី សូមអញ្ជើញទៅផ្ទៀងផ្ទាត់នៅសាលា ឃុំ សង្កាត់ ណាមួយ ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ក្នុងជុំទី៧ លើកទី១ នេះ
- ពេលទៅបើកប្រាក់ឧបត្ថម្ភជុំទី៧ លើកទី១ នៅតាមបញ្ជរវីង តម្រូវឱ្យអ្នកទទួលផលត្រូវភ្ជាប់ទៅជាមួយនូវឯកសារពាក់ព័ន្ធដូចគ្នានឹងការបើកប្រាក់ឧបត្ថម្ភលើកមុនៗផងដែរ ពិសេសប័ណ្ណសមធម៌ ដែលនៅមានសុពលភាព និងត្រូវចងចាំលេខកូដសម្ងាត់
- ករណីភ្លេចលេខសម្ងាត់ សូមទំនាក់ទំនងអ្នកទទួលបន្ទុកកម្មវិធីនៅតាមឃុំ សង្កាត់ ឬ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ។
- ក្នុងករណីប្រជាពលរដ្ឋ ឬ សាធារណជន ពិនិត្យឃើញភាពមិនប្រក្រតីណាមួយក្នុងការអនុវត្តកម្មវិធី ឬ ដកសាច់ប្រាក់មិនបាននៅតាមបញ្ជរវីងណាមួយនោះ សូម សាធារណជន និងអ្នកទទួលផលទាំងអស់ ធ្វើការទំនាក់ទំនងជាមួយអ្នកកាន់កម្មវិធីនៅតាមឃុំ សង្កាត់ ឬ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ មន្ទីរផែនការ រាជធានី ខេត្តនីមួយៗ ឬ តាមរយៈប្រព័ន្ធទូរស័ព្ទព័ត៌មានទាន់ហេតុការរបស់ នាយកដ្ឋានសុខុមាលភាពសង្គម នៃអគ្គនាយកដ្ឋានបច្ចេកទេស លេខ (០៩២ /០១៥) ២១៩ ៨៨៨

- សូម គ្រួសារក្រីក្រ និងងាយរងគ្រោះ ទាំងអស់គោរពនូវវិធានការរបស់រាជរដ្ឋាភិបាលក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលដោយអនុវត្តនូវវិធានការ ៣កុំ ៣ការពារ នៅគ្រប់ទីកន្លែង និងចូលរួមចាក់វ៉ាក់សាំងឲ្យបានគ្រប់គ្នាតាមការផ្ដល់ជូនរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវការកាត់ផ្ដាច់ខ្សែចង្វាក់នៃការរីករាលដាលជំងឺកូវីដ-១៩ និងរស់នៅក្នុងគន្លងនៃបរិបទថ្មី

ជាថ្មីម្ដងទៀត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ បណ្ដាញសារព័ត៌មាន និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រ និងជំរុញការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ឱ្យដំណើរការទៅដោយរលូន និងទទួលបានការសាទរយ៉ាងខ្លាំងពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ពិសេសប្រជាជនក្រីក្រដែលជាក្រុមជនងាយរងគ្រោះ និងកំពុងប្រឈមយ៉ាងខ្លាំងពីឥទ្ធិពលនៃជំងឺកូវីដ-១៩ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងស្ថាប័នពាក់ព័ន្ធ ជាពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ទាំងអស់មេត្តាជ្រាប និងបន្តសហការអនុវត្ត ដើម្បីឱ្យកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បន្តដំណើរការដោយរលូន និងទទួលបានជោគជ័យបន្តទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការផ្ដល់ការអន្តរាគមន៍ជំនួយសង្គមដល់ប្រជាជន ពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយមិនទុកប្រជាជនណាម្នាក់ចោល ហើយមិនមានការយកចិត្តទុកដាក់ពីរដ្ឋនោះឡើយ ។

ថ្ងៃច័ន្ទ ៤រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១